NSW GOVERNMENT

# What do I need to know if my child is suspended?

## Parent/carer information

# តើខ្ញុំត្រូវដឹងពីអ្វីខ្លះ ប្រសិនបើកូនរបស់ខ្ញុំត្រូវបានបញ្ឈប់បណ្តោះអាសន្ន?

## ព័ត៌មានសម្រាប់ឪពុកម្តាយ/អ្នកថែទាំ

### តើអ្វីជាការបញ្ឈប់បណ្តោះអាសន្ន?

ការបញ្ឈប់បណ្តោះអាសន្ន គឺនៅពេលដែលសាលារៀនប្រាប់សិស្សម្នាក់មិនឱ្យមកសាលារៀនមួយរយៈពេល។ សិស្សនៅថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី 2 អាចត្រូវបានបញ្ឈប់បណ្តោះអាសន្នរហូតដល់ទៅ 5 ថ្ងៃសិក្សា ហើយសិស្សនៅថ្នាក់ទី 3 ដល់ថ្នាក់ទី 12 អាចត្រូវបានបញ្ឈប់បណ្តោះអាសន្នរហូតដល់ទៅ 10 ថ្ងៃសិក្សា។

នាយកសាលាអាចបញ្ឈប់បណ្តោះអាសន្នសិស្សម្នាក់ ពេលណាអាកប្បកិរិយាគួរឱ្យព្រួយបារម្ភរបស់សិស្សនោះ បង្កហានិភ័យដែលមិនអាចទទួលយកបានដល់អ្នកដទៃ ឬដល់ការបង្រៀន និងការរៀនសូត្រ។

នាយកសាលាអាចបញ្ឈប់បណ្តោះអាសន្ន នៅពេលដែលពួកគេបានព្យាយាមគ្រប់គ្រងអាកប្បកិរិយាគួរឱ្យព្រួយបារម្ភរបស់សិស្សរួចហើយ ដោយមធ្យោបាយផ្សេងទៀត ហើយសាលារៀនត្រូវការពេលវេលាដើម្បីរៀបចំផែនការគាំទ្រសម្រាប់អាកប្បកិរិយា និងរៀបចំផែនការពីរបៀបរក្សាមនុស្សគ្រប់រូបឱ្យមានសុវត្ថិភាព ដោយមិនចាំបាច់ឱ្យសិស្សមានវត្តមាននៅសាលារៀន។ នាយកសាលាត្រូវគិតពិចារណាពីអាកប្បកិរិយា និងតម្រូវការនានារបស់សិស្ស នៅពេលធ្វើការសម្រេចចិត្តបញ្ឈប់បណ្តោះអាសន្ន។ ប្រសិនបើអាកប្បកិរិយាគឺធ្ងន់ធ្ងរ ឬបង្កបញ្ហាសុវត្ថិភាព កូនរបស់អ្នកអាចត្រូវបានបញ្ឈប់បណ្តោះអាសន្នជាបន្ទាន់។

### តើមានអ្វីកើតឡើងប្រសិនបើកូនរបស់ខ្ញុំត្រូវបានបញ្ឈប់បណ្តោះអាសន្ន?

នាយកសាលាត្រូវប្រាប់សិស្សដោយផ្ទាល់មាត់ កន្លែងណាដែលសមរម្យ។ ពួកគេត្រូវតែជូនដំណឹងជាបន្ទាន់ដល់ឪពុកម្តាយ ឬអ្នកថែទាំដោយផ្ទាល់មាត់ កន្លែងណាដែលអាចធ្វើទៅបាន ឬក្នុងរយៈពេល 24 ម៉ោង។ អ្នក និងកូនរបស់អ្នកត្រូវតែបានផ្តល់ឱកាសឱ្យជួបជាមួយសាលារៀន ដើម្បីឆ្លើយតបចំពោះការបញ្ឈប់បណ្តោះអាសន្ននេះ។ សាលារៀននឹងធ្វើការជាមួយអ្នកលើយុទ្ធសាស្ត្រ និងការគាំទ្រនានា ដែលអាចដាក់ឱ្យដំណើរការដើម្បីជួយកូនរបស់អ្នក។

នាយកសាលាក៏នឹងផ្តល់ឱ្យអ្នកនូវការជូនដំណឹងជាលាយលក្ខណ៍អក្សរមួយផងដែរ អំពីការបញ្ឈប់បណ្តោះអាសន្ន រួមមានហេតុផលនានាដែលកូនរបស់អ្នកត្រូវបានបញ្ឈប់បណ្តោះអាសន្ន ព័ត៌មានលម្អិត និងរយៈពេលនៃការបញ្ឈប់បណ្តោះអាសន្ន

ក្នុងអំឡុងពេលបញ្ឈប់បណ្តោះអាសន្ន កូនរបស់អ្នកនឹងមិនបានអនុញ្ញាតឱ្យមកសាលារៀនទេ។ សាលារៀននឹងផ្តល់ការគាំទ្រដល់កូនរបស់អ្នក ដើម្បីបន្តការរៀនសូត្រក្នុងអំឡុងពេលបញ្ឈប់បណ្តោះអាសន្ន ហើយនឹងទំនាក់ទំនងជាមួយអ្នក និងកូនរបស់អ្នក។ ព័ត៌មានអំពីវិធីជួយដល់សុខុមាលភាពរបស់កូនអ្នកអំឡុងពេលបញ្ឈប់បណ្តោះអាសន្ន គឺអាចរកបាន។

### ការបន្តរយៈពេលនៃការបញ្ឈប់បណ្តោះអាសន្ន

ប្រសិនបើការបញ្ឈប់បណ្តោះអាសន្ន មិនផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំផែនការគាំទ្រ ឬមានហានិភ័យសុវត្ថិភាពកំពុងបន្តកើតមានដែលមិនទាន់បានគ្រប់គ្រងនៅឡើយ នាយកសាលាអាចបន្តរយៈពេលនៃការបញ្ឈប់បណ្តោះអាសន្ន។ ឪពុកម្តាយ/អ្នកថែទាំនឹងត្រូវបានជូនដំណឹងមុនចុងបញ្ចប់នៃការបញ្ឈប់បណ្តោះអាសន្ន ប្រសិនបើវាត្រូវបានបន្ត។

### តើខ្ញុំអាចប្តឹងតវ៉ាមិនយល់ស្របចំពោះការបញ្ឈប់បណ្តោះអាសន្នបានទេ?

បាន ប្រសិនបើអ្នកជឿជាក់ថា នាយកសាលាបានធ្វើការសម្រេចចិត្តមិនយុត្តិធម៌ ឬមិនបានអនុវត្តតាមគោលនយោបាយ និងនីតិវិធីត្រឹមត្រូវ។ សូមយោងទៅធនធានបណ្តឹងតវ៉ាមិនយល់ស្រប។

ព័ត៌មានបន្ថែមស្តីពីការតស៊ូមតិសម្រាប់កូនរបស់អ្នកគឺអាចរកបាន ក៏ដូចជាធម្មនុញ្ញសហគមន៍សាលារៀន ដែលគូសបញ្ជាក់ពីវិធីនានាដើម្បីប្រាស្រ័យទាក់ទងជាមួយសាលារៀន។

### តើអ្វីជាកិច្ចប្រជុំដោះស្រាយការបញ្ឈប់បណ្តោះអាសន្ន?

កូនរបស់អ្នកនឹងត្រឡប់មកសាលារៀនវិញនៅចំថ្ងៃ ឬមុនថ្ងៃបញ្ឈប់បណ្តោះអាសន្នបញ្ចប់។ ការចូលរួមជាវិជ្ជមានរបស់អ្នកជាមួយសាលារៀន វាមានសារៈសំខាន់ណាស់ក្នុងការគ្រប់គ្រងអាកប្បកិរិយារបស់កូនអ្នក និងបង្កើតដំណោះស្រាយរួមគ្នា។ មុនពេលកូនរបស់អ្នកត្រឡប់មកសាលារៀនវិញ សាលារៀននឹងទាក់ទងមកអ្នកតាមទូរសព្ទ ដើម្បីរៀបចំកិច្ចប្រជុំដោះស្រាយមួយ ជាមួយបុគ្គលិកសាលាដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយកូនរបស់អ្នក។

កិច្ចប្រជុំអាចធ្វើឡើងដោយជួបមុខផ្ទាល់ តាមទូរសព្ទ ឬតាមអនឡាញ ក្នុងទម្រង់ដែលនឹងផ្តល់ឱកាសល្អបំផុតសម្រាប់ការពិភាក្សាជាវិជ្ជមាន។ កិច្ចប្រជុំនឹងនិយាយអំពីរបៀបដែលអ្នកអាចធ្វើការរួមគ្នា ដើម្បីគាំទ្រកូនរបស់អ្នកនៅពេលពួកគេត្រឡប់ទៅសាលារៀនវិញ។ អ្នកអាចនាំអ្នកគាំទ្រម្នាក់មកជាមួយអ្នកនៅឯកិច្ចប្រជុំ។ អ្នកគាំទ្រអាចជានរណាម្នាក់ដែលអាចផ្តល់ឱ្យអ្នក និង/ឬកូនរបស់អ្នកនូវការគាំទ្រជាក់ស្តែង និង/ឬការគាំទ្រផ្លូវចិត្ត។

ចំពោះអាកប្បកិរិយាគួរឱ្យព្រួយបារម្ភដែលតម្រូវយុទ្ធសាស្ត្រ និងការគាំទ្របន្ថែមទៀត សាលារៀននឹងធ្វើការជាមួយអ្នក និងកូនរបស់អ្នក ក្នុងគោលបំណងបង្កើតផែនការមួយដើម្បីគាំទ្រពួកគេ និងកាត់បន្ថយហានិភ័យនានា។ កូនរបស់អ្នកប្រហែលជាមានផែនការមួយដែលបានដាក់ដំណើរការរួចហើយរួចហើយ។ ប្រសិនបើមានផែនការមួយបានដាក់ដំណើរការរួចហើយ វានឹងត្រូវបានកែសម្រួល ដើម្បីជួយគាំទ្រកូនរបស់អ្នក។ ផែនការនេះនឹងត្រូវបានចែករំលែកជាមួយអ្នក និងជាមួយបុគ្គលិកផ្សេងទៀត នៅសាលារៀនដែលគាំទ្រកូនរបស់អ្នក។

### ចុះប្រសិនបើអាកប្បកិរិយានោះកើតឡើងម្តងទៀត?

ប្រសិនបើអាកប្បកិរិយាគួរឱ្យព្រួយបារម្ភកើតឡើងម្តងទៀត នាយកសាលា និងក្រុមគាំទ្រការរៀនសូត្ររបស់សាលា នឹងព្យាយាមកំណត់វិធីផ្សេងទៀត ដើម្បីគាំទ្រដល់ការរៀនសូត្ររបស់កូនអ្នក ដែលអាចរួមមានការបញ្ឈប់បណ្តោះអាសន្នមួយផ្សេងទៀត។ នេះអាចរួមបញ្ចូលការស្នើសុំអ្នកជំនាញមកពីក្នុងក្រសួង ដើម្បីជួយផ្តល់ការគាំទ្រ។

### តើខ្ញុំអាចទទួលបានព័ត៌មានអ្វីខ្លះពីសាលារៀន?

អ្នកអាចសួរសាលារៀនសម្រាប់ព័ត៌មានបន្ថែម អំពីអ្វីដែលបានកើតឡើង និងពីមូលហេតុ។ សាលារៀនគួរតែពន្យល់ដល់អ្នកអំពីហេតុផលនៅពីក្រោយការសម្រេចចិត្តណាមួយ សកម្មភាពនឹងកើតឡើង និងអ្វីដែលត្រូវធ្វើប្រសិនបើអ្នកមានបញ្ហា។

### សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកមានបំណងចង់ទាក់ទងមកសាលារៀន ហើយត្រូវការជំនួយផ្នែកភាសាអង់គ្លេស សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទតាមលេខ 131 450 ប្រាប់ពួកគេពីភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យការីទូរសព្ទទូរសព្ទទៅសាលារៀន។ ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយអ្នកនៅក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។